YUNNAN DAILY PRESS GROUP
No.130

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

YUNNAN DAILY PRESS GROUP
english.yunnan.cn

ឆ្នាំទី 25 លេខ 7473 ថ្ងៃសុក្រ ទី03 ខែវិច្ឆិកា ឆ្នាំ 2017

# រួមគ្នាស្ថាបនា"ខ្សែក្រវាត់មួយនិងផ្លូវមួយ" ចែករំលែកគ្នាអំពីកាលានុវត្តភាពកាន់តែច្រើនដែលនាំមកដោយប្រទេសចិន

***អ្នករៀបរៀង : កាលពីថ្ងៃទី១៨ ដល់ទី២៤ខែតុលាសមាជបក្សកុម្មុយនីស្តចិនលើកទី១៩បានរៀបចំនៅក្រុងប៉េកាំង ។ ឯកឧត្តមស៊ី ជីនភីង អគ្គលេខាធិការនៃគណៈកម្មាធិការ មជ្ឈិមបក្សកុម្មុយនីស្តចិនបានថ្លែងក្នុងរបាយការណ៍ថា ប្រទេសចិនប្រកាន់ ខ្ជាប់នូវគោលនយោបាយមូលដ្ឋាន នៃការបើកទូលាយចំពោះបរទេស ប្រកាន់ខ្ជាប់នូវការបើកខ្លោងទ្វារ ប្រទេស ដើម្បីជំរុញការអភិវឌ្ឍន៍ និងជំរុញយ៉ាងសកម្មនូវកិច្ចសហប្រតិបត្តិការអន្តរជាតិ "ខ្សែក្រវាត់មួយ និងផ្លូវមួយ" ។ សមាជបក្សកុម្មុយនីស្តចិនលើកទី១៩ នេះបានទទួលនូវការវាយតម្លៃខ្ពស់ពីអ្នកនយោបាយអ្នកជំនាញការ និងអ្នកសិក្សាស្រាវជ្រាវរបស់បណ្តាប្រទេសនានា ។ ពេលនេះយើងខ្ញុំសូមបង្ហាញ ជូនលោកអ្នកអំពីកាលានុវត្តភាព នៃការអភិវឌ្ឍសម្រាប់ប្រទេសពាក់ព័ន្ធ ដែលនាំមកដោយគំនិតផ្តួចផ្តើម "ខ្សែ ក្រវាត់មួយ និងផ្លូវមួយ" ។***

## ប្រធានសមាគមមិត្តភាពកម្ពុជា-ចិនមានជំនឿទុកចិត្តចំពោះអនាគតរបស់ប្រទេសចិន



*លោកឯក សំអុល ប្រធានសមាគមមិត្តភាពកម្ពុជា-ចិន បានផ្តល់បទសម្ភាសន៍ ជាមួយអ្នកសារព័ត៌មាន អំពីការរៀបចំសមាជបក្សកុម្មុយនិស្តចិន លើកទី១៩ កាលពីពេលថ្មីៗនេះ (រូបថតដោយ យូ ជាំងនីង)*

ប៉ុន្មានថ្ងៃមកនេះ គ្រប់មជ្ឈដ្ឋានក្នុងសង្គមខ្មែរចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការរៀបចំសមាជបក្សកុម្មុយនីស្តចិនលើកទី១៩ ។ លោកឯក សំអុល ប្រធានសមាគមមិត្តភាពកម្ពុជា-ចិន បានផ្តល់បទសម្ភាសន៍ជាមួយអ្នកសារព័ត៌មានថា ខ្ញុំជឿជាក់ថា ក្នុងរយៈពេលប្រាំឆ្នាំខាងមុខ គណបក្សកុម្មុយនីស្តចិនដែលដឹកនាំដោយ ឯកឧត្តម ស៊ីជីនភីង នឹងអាចដឹកនាំប្រទេសចិនឱ្យដើរ ឆ្ពោះទៅមុខកាន់តែឆាប់រហ័ស ! ប្រទេសចិននឹងអាចមានអនាគតកាន់តែភ្លឺស្វាង !

លោកបន្តទៀតថា ទន្ទឹមនឹងការស្ថាបនា "ខ្សែក្រវាត់មួយ និងផ្លូវមួយ" មានសហគ្រាសចិនកាន់តែច្រើនទៅធ្វើវិនិយោគនៅប្រទេសកម្ពុជា ។ ប្រាំឆ្នាំចុងក្រោយនេះ កម្ពុជាបានទទួលនូវការរីកចម្រើនច្រើន ។ លោកសង្ឃឹមថា ក្នុងរយៈពេលប្រាំឆ្នាំខាងមុខ ភាគីកម្ពុជានិងចិននឹងអាចរួមសហការគ្នាលើគម្រោងកាន់តែច្រើន រួមមានវិស័យសេដ្ឋកិច្ច វប្បធម៌ និងការកាត់បន្ថយភាពក្រីក្រជាដើម ដើម្បីចែករំលែកគ្នាអំពីសមិទ្ធផលនៃការអភិវឌ្ឍ៕

**ដោយ យូ ជាំងនីង**

## បេក្ខជនបេក្ខនារីនៃការប្រកួត "ស្ពានភាសាចិន" យកចិត្តទុកដាក់ចំពោះសមាជបក្សកុម្មុយនិស្តចិនលើកទី១៩

កញ្ញាតាំង ឆៃឡេង បេក្ខនារីខ្មែរដែលចូលរួមការប្រកួត"ស្ពានភាសាចិន"ក្នុងសាកលវិទ្យាល័យគរុកោសល្យខេត្តយូនណាននាថ្ងៃទី ២១ ខែតុលា បានប្រាប់អ្នកកាសែតថា ពិតជាហួសពីការប៉ាន់ស្មានរបស់ខ្ញុំណាស់ វេបសាយ"ស្ពានយូនណាន"បានបើកបង្អួចថ្មីមួយសម្រាប់ឱ្យខ្ញុំមានការយល់ដឹងកាន់តែច្រើនអំពីប្រទេសចិន ។ ជាពិសេសវេបសាយនេះ បានផ្សាយព័ត៌មានជាភាសាអង់គ្លេសឱ្យទាន់ពេលវេលាអំពីសមាជបក្សកុម្មុយនិស្តចិនដែលកំពុងរៀបចំនៅក្រុងប៉េកាំងនោះ។

ប៉ុន្មានថ្ងៃមកនេះ ក្រុមហ៊ុនកាសែតយូនណាន ដេលី គ្រុប បានរួមសហការគ្នាជាមួយប្រព័ន្ធផ្សព្វផ្សាយនៃប្រទេសចំនួនប្រាំបី រួមមានប្រទេសអាមេរិក មីយ៉ាន់ម៉ា ឡាវ ថៃ កម្ពុជា ឥណ្ឌូណេស៊ី ឥណ្ឌា និងបង់ក្លាដែសដើម្បីចុះផ្សាយព័ត៌មានអំពីសមាជបក្សកុម្មុយនិស្តចិនលើកទី ១៩ តាមរយៈវិធីផ្សព្វផ្សាយគ្រប់ប្រភេទ រួមមានទំព័រកាសែតពិសេស"ខេត្តយូនណានប្រទេសចិន"ចំនួន១៣វេបសាយ "ស្ពានយូនណាន" ប្រព័ន្ធមីឌាទំនាក់ទំនង នៅក្រៅប្រទេសទស្សនាវដ្តី "សិរីមង្គល"ជាភាសាភូមាទស្សនាវដ្តី"ចម្ប៉ា" ជា ភាសាឡាវទស្សនាវដ្តី"ទន្លេមេគង្គ "ជាភាសាថៃ និងទស្សនាវដ្តី"ខ្មែរ"ជា ខេមរភាសា ។



*កញ្ញា តាំង ឆៃឡេង បេក្ខនារី ខ្មែរដែលចូលរួមការប្រកួត " ស្ពានភាសាចិន " ក្នុង សាកលវិទ្យាល័យគរុកោសល្យ ខេត្តយូនណាននាថ្ងៃទី ២១ ខែតុលា កាលពីប៉ុន្មាន ថ្ងៃមុនសម្រាប់រឿង បេក្ខជនបេក្ខនារីនៃការប្រកួត " ស្ពានភាសាចិន " យកចិត្តទុកដាក់ចំពោះ សមាជបក្សកុម្មុយនិស្តចិនលើកទី ១៩*

បច្ចុប្បន្ន ការប្រកួត"ស្ពានភាសាចិន"សម្រាប់សិស្សមធ្យមសិក្សាកំពុងរៀបចំនៅក្នុងទីក្រុងគុនមីងនៃខេត្តយូនណាន ។ ក្រុមហ៊ុនកាសែតយូនណាន ដេលី គ្រុប បានរៀបចំឯកសារផ្សព្វផ្សាយអំពី"ពាក្យថ្មីចិន" ព័ត៌មាននៃប្រព័ន្ធមីឌាថ្មីនៅក្រៅប្រទេស និងបាកូដអាសយដ្ឋានវេបសាយ"ស្ពានយូនណាន" ដើម្បីផ្តល់ជូនបេក្ខជនបេក្ខនារីដែលមកពីប្រទេសនិងតំបន់ផ្សេងៗលើពិភពលោក ។ តាមរយៈវិធីផ្សព្វផ្សាយបែបនេះ បេក្ខជនបេក្ខនារីដែលចូលរួមការប្រកួត"ស្ពានភាសាចិន"អាចមានការយល់ដឹងកាន់តែច្រើនអំពីព័ត៌មានថ្មីៗនៃសមាជបក្សកុម្មុយនិស្តចិនលើកទី ១៩ ព្រមទាំងសមិទ្ធផលនៃការអភិវឌ្ឍសេដ្ឋកិច្ចវប្បធម៌ និងទេសចរណ៍របស់ ខេត្តយូនណាន ក៏ដូចជារបស់ប្រទេសចិនទាំងមូលផងដែរ ៕ **ដោយចាំង យូគូ**

## អ្នកនាំពាក្យក្រសួងការបរទេសចិនបកស្រាយអំពីការដាក់បញ្ចូល "ខ្សែក្រវាត់មួយនិងផ្លូវមួយ" ក្នុងលក្ខន្តិកៈគណបក្សកុម្មុយនិស្តចិន

នៅថ្ងៃទី ២៦ ខែតុលា លោក ឌឹស្វងអ្នកនាំពាក្យនៃក្រសួងការបរទេសចិន បានថ្លែងក្នុងសន្និសីទកាសែតថា សមាជបក្សកុម្មុយនិស្តចិនលើកទី១៩ បានអនុម័តសេចក្តីសម្រេចអំពី"ការធ្វើវិសោធនកម្មលក្ខន្តិកៈគណបក្ស កុម្មុយនិស្តចិន"ដែលនឹងដាក់បញ្ចូល គំនិតផ្តួចផ្តើម"ខ្សែក្រវាត់មួយ និងផ្លូវមួយ"ទៅក្នុងលក្ខន្តិកៈគណបក្សកុម្មុយនិស្តចិន ។ នេះបានបង្ហាញឱ្យឃើញពីសេចក្តីប្តេជ្ញាចិត្ត និងជំនឿចិត្តរបស់ប្រទេសចិនពោលគឺ ក្រោមការដឹកនាំពីគណបក្សកុម្មុយនិស្តចិនប្រទេសចិននឹងយកចិត្តទុកដាក់កម្រិតខ្ពស់ចំពោះការស្ថាបនា"ខ្សែក្រវាត់មួយនិងផ្លូវមួយ" និងជំរុញយ៉ាងម៉ឺងម៉ាត់នូវកិច្ចសហប្រតិបត្តិការអន្តរជាតិតាមបណ្តោយ"ខ្សែក្រវាត់មួយនិងផ្លូវមួយ" ។

លោកមានប្រសាសន៍ថា ការដាក់បញ្ចូលគំនិតផ្តួចផ្តើម"ខ្សែក្រវាត់មួយ និងផ្លូវមួយ"ទៅក្នុងលក្ខន្តិកៈគណបក្សកុម្មុយនិស្តចិនប្រាកដជានឹងអាចចង្អុលទិសដៅ និងចាក់បញ្ចូលកម្លាំងចលករថ្មីសម្រាប់ឱ្យយើងរួមគ្នាជាមួយភាគីនានាដើម្បីកសាង "ខ្សែក្រវាត់មួយ និងផ្លូវមួយ" ជំរុញការបង្កើតទំនាក់ទំនងអន្តរជាតិបែបថ្មី និងរួមគ្នាស្ថាបនាសហគមន៍រួមវាសនាមនុស្សជាតិក្នុងយុគសម័យថ្មីនេះ ៕

**ដោយ យ៉ាន ជីមីន (ទីភ្នាក់ងារព័ត៌មានស៊ីនហួចិន)**

## របាយការណ៍នៃសមាជបក្សកុម្មុយនីស្តចិនលើកទី១៩ទទួលការវាយតម្លៃខ្ពស់

តាមរបាយការណ៍នៃសមាជបក្សកុម្មុយនីស្តចិនលើកទី១៩ បានឱ្យដឹងថា "ការប្រកាន់ខ្ជាប់នូវការរួមរស់នៅជាមួយគ្នាដោយសុខដុមរមនារវាងមនុស្សជាតិនិងធម្មជាតិ" បានត្រូវដាក់បញ្ចូលក្នុងគោលលំនាំមូលដ្ឋានអំពីការកសាង និងអភិវឌ្ឍន៍សង្គមនិយមដែលមានលក្ខណៈពិសេសចិនក្នុងយុគសម័យថ្មី ។ ចំពោះបញ្ហានេះ តំណាងខេត្តយូនណានបានបញ្ចេញយោបល់រួមថា ធនធានដែលមានតម្លៃជាងគេរបស់ខេត្តយូនណាន គឺអេកូបរិស្ថានដ៏ល្អប្រសើរ ។ យើងត្រូវខិតខំថែរក្សាអេកូ-បរិស្ថានដូចថែរក្សាភ្នែកទាំងគូរបស់យើងអញ្ចឹង ហើយត្រូវផ្តល់អាទិភាពដល់ការថែរក្សាអេកូ-បរិស្ថាននៃបឹងទានឈី និងបឹងផ្សេងៗទៀតលើខ្ពង់រាប ធ្វើការគ្រប់គ្រងដោយមានលក្ខណៈវិទ្យាសាស្ត្រ មានលក្ខណៈជាប្រព័ន្ធ គ្រប់គ្រងជារួម និងស្របតាមច្បាប់ ព្រមទាំងជំរុញការអនុវត្តឱ្យកាន់តែស៊ីជម្រៅនិងគ្រប់ជ្រុងជ្រោយតាមរបបទំនួលខុសត្រូវចំពោះការថែរក្សាបរិស្ថានទន្លេ និងយន្តការថែរក្សាអេកូបរិស្ថានតាមដងទន្លេ ដំណើរការត្រួតពិនិត្យធនធានអេកូ-ធម្មជាតិ ដោយឈានមុខ ចាត់វិធានការចម្រុះសម្រាប់ថែរក្សាបរិស្ថានភ្នំ ទឹក ព្រៃឈើ បឹងបួ និងវាលស្មៅ ដើម្បីធ្វើឱ្យខេត្តយូនណានមានខ្យល់អាកាសកាន់តែបរិសុទ្ធ មានដីស្រែកាន់តែមានពណ៌បៃតង និងមានទឹកកាន់តែថ្លាឈ្វេង ។

របាយការណ៍នៃសមាជបក្សកុម្មុយនិស្តចិនលើកទី ១៩ បានលើកឡើងថា"ត្រូវជំរុញឱ្យប្រជាជនគ្រប់ជនជាតិឱបគ្នាយ៉ាងស្អិតដូចគ្រាប់ទទឹមអ៊ីចឹង" ។ នេះបានទទួលការចាប់អារម្មណ៍យ៉ាងខ្លាំងពីតំណាងខេត្តយូនណាន ។ តំណាងខេត្តយូនណានបានសម្តែងឆន្ទៈមោះមុតថា យើងទាំងអស់គ្នានឹងខិតខំកសាងខេត្តយូនណានឱ្យទៅជាតំបន់គំរូនៃការរួមសាមគ្គីគ្នាគ្រប់ជនជាតិជំរុញការអភិវឌ្ឍបុព្វហេតុរួមសាមគ្គីគ្នាគ្រប់ជនជាតិ ផ្តោតសំខាន់ទៅលើការកាត់បន្ថយភាពក្រីក្រដោយតម្រង់ទិសបន្តជំរុញយ៉ាងពេញទំហឹងនូវការអនុវត្តការងារកាត់បន្ថយភាពក្រីក្រកុំឱ្យបងប្អូនជនជាតិភាគតិចណាមួយដើរនៅក្រោយគេ ។

របាយការណ៍នៃសមាជបក្សកុម្មុយនិស្តចិនលើកទី១៩ បានទទួលការវាយតម្លៃខ្ពស់ពីមជ្ឈដ្ឋានវប្បធម៌នៃខេត្តយូនណាន ។ ប្រជាជនខេត្តយូនណានបានឯកភាពគ្នាថា ការកសាងផ្លូវអភិវឌ្ឍន៍វប្បធម៌សង្គមនិយមដែលមានលក្ខណៈពិសេស ចិនបានសំណូមពរឱ្យយើងទាំងអស់គ្នាជំរុញការអភិវឌ្ឍបុព្វហេតុវប្បធម៌ដោយឈរលើស្ថានភាពជាក់ស្តែងច្របាច់បញ្ចូលគ្នានូវបទពិសោធន៍ប្រវត្តិសាស្ត្រនិងស្ថានភាពបច្ចុប្បន្ន ជំរុញការស៊ីសង្វាក់គ្នារវាងវប្បធម៌ចិននិងបរទេសបន្តផ្សព្វផ្សាយពីវប្បធម៌ប្រពៃណីដ៏ល្អប្រសើរនិងបម្រើផលប្រយោជន៍របស់ប្រជាជន ៕



*បឹង លូគូ នៅតំបន់ប្រសព្វនៃខេត្ត យូនណាន និង ខេត្តស៊ីឈួន ត្រូវការពារយ៉ាងល្អ ។ នៅទីនោះទូកដែល មានម៉ាស៊ីនមិនត្រូវបានអនុញ្ញាតឱ្យធ្វើ ចរាចរណ៍ ដើម្បីបង្ការការបំភាយ ឧស្ម័នពុល (រូបថត ដោយ Li Qiuming )*

## លោកហឺ លាំងហួយៈ ខេត្តយូនណាននឹងពន្លឿនការតភ្ជាប់យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាមួយប្រទេសកម្ពុជា

លោក ហឺ លាំងហួយ ប្រធានមន្ទីរពាណិជ្ជកម្មខេត្តយូនណាននិងជាតំណាងសមាជបក្សកុម្មុយនីស្តលើក ទី១៩ បានថ្លែងថា ក្រោមក្របខ័ណ្ឌនៃទំនាក់ទំនងការទូត យុទ្ធសាស្ត្រអភិវឌ្ឍន៍ និងគោលនយោបាយរបស់ រដ្ឋាភិបាលចិនខេត្តយូនណាននឹងបង្កើតយន្តការស្តីពីកិច្ចសហប្រតិបត្តិការជាមួយប្រទេសអាស៊ីខាងត្បូងនិង អាស៊ីអាគ្នេយ៍ជំរុញយ៉ាងសកម្មនូវការតភ្ជាប់នឹងប្រទេសកម្ពុជា ដើម្បីតភ្ជាប់គំនិតផ្តួចផ្តើម "ខ្សែក្រវាត់មួយ និងផ្លូវមួយ" ទៅនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់ប្រទេសកម្ពុជាសម្រាប់ជំរុញ ការអភិវឌ្ឍរួមគ្នា ។

លោកបន្តទៀតថា របាយការណ៍នៃសមាជបក្សកុម្មុយនីស្តចិនលើកទី១៩ បានលើកឡើងយ៉ាងជាក់ច្បាស់ថា ប្រទេសចិននឹងប្រកាន់ខ្ជាប់នូវការជំរុញការបង្កើតសហគមន៍រួមវាសនាមនុស្សជាតិហើយជំរុញឱ្យបង្កើតជានិម្មាបនកម្មថ្មីនៃការបើកទូលាយគ្រប់ជ្រុងជ្រោយ ។ មធ្យោបាយជាក់ស្តែងសម្រាប់សម្រេចគោលដៅទាំងពីរគឺគំនិតផ្តួចផ្តើម "ខ្សែក្រវាត់មួយ និងផ្លូវមួយ" ។

លោកសង្កត់ធ្ងន់ថា ខេត្តយូនណានជាខេត្តសំខាន់មួយដែលមានទីតាំង ស្ថិតនៅតាម "ខ្សែក្រវាត់មួយ និងផ្លូវមួយ" ហើយត្រូវតែកំណត់ផែនការដើរតួនាទីនាំមុខ និងខិតខំជំរុញការតភ្ជាប់ទៅ នឹងប្រទេសកម្ពុជា លើវិស័យចំនួនបួន គឺការតភ្ជាប់យុទ្ធសាស្ត្រអភិវឌ្ឍន៍ការតភ្ជាប់ហេដ្ឋា- រចនាសម្ព័ន្ធ ការពង្រឹងកិច្ចសហប្រតិបត្តិការសមត្ថភាពផលិត និងកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មអន្តរជាតិ។

លោកបានគូសបញ្ជាក់ថា ប៉ុន្មានឆ្នាំនេះ ខេត្តយូនណានបានចូលរួមយ៉ាងសកម្មក្នុងការផ្តល់សេវាកម្មដល់សហគ្រាសដែល "ដើរចេញទៅក្រៅ" លើកទឹកចិត្តសហគ្រាសខេត្តយូនណានឱ្យខិតខំបំពេញភារកិច្ចសង្គមនៅក្នុងប្រទេសជាទីដៅវិនិយោគ និងបម្រើផលប្រយោជន៍ជូនសង្គមនិងប្រជាជននៃបណ្តាប្រទេសនានា ៕

**(ដកស្រង់ចេញពីកាសែតខ្មែរដេលី)**